# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### កំណត់ហេតុកិច្ចប្រជុំពិភាក្សា ពិគ្រោះយោបល់

### ស្តីពី

### របាយការណ៍ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង លើគំរោងសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មរ៉ែមាស របស់ក្រុមហ៊ុន DELCOM (KAMPUCHEA) PTE. LTD. ស្ថិតនៅតំបន់ភ្នំដែក ឃុំរម្យទម ស្រុករវៀង ខេត្តព្រះវិហារ

Draft

កាលពីវេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹកថ្ងៃទីដប់ពីរ ខែសីហា ឆ្នាំពីរពាន់ដប់ នៅសាលាខេត្តព្រះវិហារ មានបើកកិច្ចប្រជុំពិភាក្សាមួយ លើបទបង្ហាញរបាយការណ៍ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង លើគំរោងសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មរ៉ែមាស ស្ថិតនៅតំបន់ភ្នំដែក ឃុំរម្យទម ស្រុករវៀង ខេត្តព្រះវិហារ របស់ក្រុមហ៊ុន **Delcom (Kampuchea) PTE. LTD.** ក្រោមអធិបតីភាព ឯកឧត្តម **ស៊ុយ សេរិទ្ធ** អភិបាលរងខេត្តព្រះវិហារ ។

សមាសភាពអញ្ជើញ ចូលរួមមាន:

| | | |
|---|---|---|
| ១-លោក | ខួយ ឃុនហ៊ី | នាយករដ្ឋបាល សាលាខេត្តព្រះវិហារ |
| ២- លោក | លី សុពណ៌-មុនី | នាយក GCF |
| ៣- លោក | ពីង ទ្រីដា | ប្រធានមន្ទីរកសិកម្មខេត្តព្រះវិហារ |
| ៤- លោក | ស្រំ ណងនី | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តព្រះវិហារ |
| ៥- លោក | ខួយ ឃុនរដ្ឋ | ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ |
| ៦- លោក | នង ខេមរិន្ទ | នាយរងរដ្ឋបាលព្រៃឈើខេត្តព្រះវិហារ |
| ៧- លោក | ឯ សារ៉ូ | អភិបាលស្រុករវៀង |
| ៨- លោក | ស្រ៊ុយ សាទី | នាយករងទីចាត់ការអន្តរវិស័យ សាលាខេត្តព្រះវិហារ |
| ៩- លោក | យ៉ុង គីមពឿង | នាយករង ទីចាត់ការរដ្ឋបាល |
| ១០-លោក | ថៅ សុង | ប្រធានការិយាល័យ ទីចាត់ការរដ្ឋបាល |

១១- លោក ញ៉ែម ប៊ុនថា តំណាងក្រុមហ៊ុន **Delcom (Kampuchea) PTE. LTD.**

១២- លោក ចាន់ សំអុល តំណាងក្រុមហ៊ុន **Delcom (Kampuchea) PTE. LTD.**

អង្គប្រជុំបានចាប់ផ្តើមឡើងដោយពាក្យស្វាគមន៍របស់ ឯកឧត្តម **ស៊ុយ សេរិទ្ធ** អភិបាលរងខេត្តព្រះវិហារ។ បន្ទាប់មក បណ្ឌិត **លី សុពណ៌-មុនី** នាយកក្រុមហ៊ុន **ហ្គ្រីន ខនសាល់ថិនស៊ី ហ្វឹម** បានពិពណ៌នា ដោយសង្ខេបអំពីគំរោងស្នើសុំដីធ្វើអាជីវកម្មរ៉ែមាស របស់ក្រុមហ៊ុន **Delcom (Kampuchea) PTE. LTD.** ដល់សមាជិកនៃអង្គប្រជុំទាំងអស់ ។

បណ្ឌិត **លី សុពណ៌-មុនី :** បានមានប្រសាសន៍ថា ក្រុមហ៊ុន **Delcom (Kampuchea) PTE. LTD.** បានស្នើសុំដីសម្បទានសេដ្ឋកិច្ចរ៉ែមាសមានទំហំ ១០០ ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ភ្នំដែក ឃុំរម្យទម ស្រុករវៀង ខេត្តព្រះវិហារ។ ដីនេះព្រំប្រទល់ខាងជើង ស្ថិតនៅចន្លោះចំណុចនិយាមកា (**A**) ៤៨៩៨៣៩ ១៤៧៩០០០ និង (**B**) ៤៩៣៨៣៩ ១៤៧៩០០០ ខាងកើតស្ថិតក្នុងចន្លោះចំណុចនិយាមកា (**B**) ៤៩៣៨៣៩ ១៤៧៩០០០ និង(**C**) ៤៩៣៨៣៩ ១៤៧៨៧៥០ ចំណែក ខាងត្បូងស្ថិតក្នុងចន្លោះចំណុចនិយាមកា (**C**) ៤៩៣៨៣៩ ១៤៧៨៧៥០ និង (**D**) ៤៨៩៨៣៩ ១៤៧៨៧៥០។ រីឯ ខាងលិចស្ថិតក្នុងចន្លោះចំណុចនិយាមកា (**A**) ៤៩៩៨៣៩ ១៤៧៩០០០ និង (**D**) ៤៩៩៨៣៩ ១៤៧៨៧៥០។ ក្រុមហ៊ុន **Delcom (Kampuchea) PTE. LTD.** ជាក្រុមហ៊ុនសាជីវកម្មបរទេស (កម្ពុជា-ចិន) បានចុះបញ្ជីការនៅក្រសួងពាណិជ្ជកម្ម ជាមួយនឹងការដាក់ដើមទុនវិនិយោគដំបូងចំនួន ៥០០.០០០.០០០ រៀល នៅថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០១០។ ក្រុមហ៊ុននេះបានទទួលអាជ្ញាប័ណ្ណស្វែងរុករករ៉ែពី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បីធ្វើការស្រាវជ្រាវលើរ៉ែមាស ក្រោមលិខិតលេខ ៩៦៩ ឧរថ.ធរ.អប ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៩ លើផ្ទៃដី សរុបចំនួន ១០០ ហិកតា។ តាមលិខិតបទដ្ឋានច្បាប់ អាជ្ញាប័ណ្ណស្វែងរុករករ៉ែមាសនៅតំបន់ភ្នំដែក ក្នុងករណីសំណើវិនិយោគសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែមាស និងឯកសារច្បាប់ដែលក្រុមហ៊ុន **Delcom (Kampuchea) PTE. LTD.** ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។ មុននឹងឈានទៅធ្វើអាជីវកម្មរ៉ែមាស តាមច្បាប់របស់ក្រសួងបរិស្ថាន ការសិក្សាទៅលើគំរោងធ្វើអាជីវកម្មរ៉ែមាសនៅក្នុងតំបន់នេះវាជះឥទ្ធិពលខ្លាំង ដូចនេះបានជាក្រុមហ៊ុន **Delcom (Kampuchea) PTE. LTD.** បានសហការជាមួយក្រុមហ៊ុន ហ្គ្រីន ដើម្បីចុះធ្វើការទៅតាមការណែនាំរបស់នាយកដ្ឋាន **EIA** របស់ក្រសួងបរិស្ថាន។

កាលពីថ្ងៃទី ១៥-១៧ ខែ កក្កដា ឆ្នាំ ២០១០ ក្រុមការងារ ហ្គ្រីន បានចុះទៅដល់តំបន់នេះ តែក្រុមហ៊ុនមិនទាន់ឈានទៅដល់ការធ្វើអាជីវកម្ម បានន័យថា រាល់គ្រឿងចក្រ និងសម្ភារៈផ្សេងៗ ពាក់ព័ន្ធទៅដល់ដំណើរការធ្វើអាជីវកម្មនឹងពុំបាននាំចូលទេ។ ដូច្នេះការសិក្សារបស់យើងមិនបានស៊ីជំរៅលំអិត ទៅលើប្រព័ន្ធផលិតកម្មរបស់ក្រុមហ៊ុនទេ ដូចនេះយើងមើលទៅលើធនធានអេកូឡូស៊ី ពាក់ព័ន្ធនឹងលទ្ធផលនៃការសិក្សា

Draft

នៅក្នុងសិលាមេ ឬលក្ខណៈភូគព្ភសាស្ត្ររបស់ដី ១០០ហិកតា គឺ (១) Granodiorite ចំនួន ២ហិកតា ស្មើនឹង ២ ភាគរយ (២) No Classifiec rock ចំនួន ៤២ហិកតា ស្មើនឹង ៤២ភាគរយ (៣) Pediments ចំនួន ២៨ហិកតា ស្មើនឹង ២៨ភាគរយ និង (៤) Peneplain laterite deposits ចំនួន ២៨ ហិកតា ស្មើនឹង ២៨ភាគរយ នៃផ្ទៃដីសរុប។ ចំពោះចំណាត់ថ្នាក់ប្រភេទដីក្នុងតំបន់សម្បទានមាន ០២ប្រភេទគឺ (១) Grey Hydromorphics ចំនួន ៤៩ ហិកតា ស្មើនឹង ៤៩ ភាគរយ និង (២) Plinthite podzols ចំនួន ៥១ ហិកតា ស្មើនឹង ៥១ ភាគរយ នៃផ្ទៃដីសរុប។ ដោយសារតែទំហំផ្ទៃដីនេះតូច ដូចនេះការសិក្សារបស់យើងមិនបានធ្វើការអង្កេតតាមរយៈការហោះហើរជាក់ស្តែងទេ ប៉ុន្តែយើងបានប្រើប្រាស់ប្រព័ន្ធទិន្នន័យផែនទីបួនជំនាន់ៈ នៅឆ្នាំ ១៩៩២-៩៣ និង ១៩៩៦-៩៧ របស់ MRC យើងចាត់ទុកថាជាដីដែលមានគំរបព្រៃ ដោយឡែកនៅឆ្នាំ ២០០២ ពេលដែលរដ្ឋបាលព្រៃឈើសហការជាមួយសមិទ្ធិរ៉ៃទៅលើរូបភាពផ្កាយរណប ដូច្នេះសារព័ន្ធរុក្ខជាតិមានពីរប្រភេទគឺ ព្រៃស្រោង ចំនួន ១០ហិកតា ស្មើនឹង ១០ភាគរយ និង ព្រៃល្បោះ ចំនួន ៩០ហិកតា ស្មើនឹង ៩០ ភាគរយ ហើយនៅឆ្នាំ២០០៦ យើងឃើញថាគំរបព្រៃគ្មានការប្រែប្រួលទេ។ ចំណាត់ថ្នាក់ដីជាតិរបស់ដីចាត់ទុកថា មានពីរប្រភេទគឺ (១) High productivity soil ចំនួន ៤៦ ហិកតាស្មើនឹង ៤០ ភាគរយ និង (២) Low productivity soil ចំនួន ៥៤ ហិកតា ស្មើនឹង ៥៤ ភាគរយ នៃផ្ទៃដីសរុប។

ក្រុមការងារអេកូឡូស៊ីបានធ្វើការអង្កេតទៅលើសារព័ន្ធរុក្ខជាតិចំនួន ១២ ឡូតិ៍ (ដែលមានព្រៃពាក់កណ្តាលស្រោងចំនួន ០៤ និងព្រៃល្បោះចំនួន ០៨) ដែលមាននៅក្នុងចំងាយ ៥០ម៉ែត្រ សងខាងគន្លង ដែលការអង្កេតនេះបានធ្វើឡើង នៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១០ ការធ្វើចំណាត់ថ្នាក់ដោយរដ្ឋបាលព្រៃឈើថា ១០ហិកតា ជាព្រៃស្រោង ពេលក្រុមការងារចុះទៅពិនិត្យជាក់ស្តែង ប្រភេទព្រៃស្រោងត្រូវបានអោយចំណាត់ថ្នាក់ម្តងទៀតថាជាព្រៃពាក់កណ្តាលស្រោងវិញ។ ដោយផ្អែកទៅលើការអង្កេត និងការវាយតំលៃទៅលើប្រភេទព្រៃ បង្ហាញថា (១) ប្រភេទព្រៃល្បោះ ស្រទាប់ទី១ មានកំពស់ទី៩-១៤ម និងស្រទាប់ទី២ មានកំពស់ទី៥-៨។ រីឯរុក្ខជាតិថ្នាក់ក្រោម ជាស្មៅព្រិច ស្បូវ និងកូនឈើតូចៗ (២) ព្រៃពាក់កណ្តាលស្រោង ស្រទាប់ទី១ មានកំពស់ ពី១០-១៨ម និងស្រទាប់ទី២ មានកំពស់ពី ៨-១០ម។ រីឯរចនាសម្ព័ន្ធថ្នាក់ក្រោមមានប្រភេទកូនឈើតូចៗ និងស្មៅតិចតួចៗ។ បើតាមការអង្កេតព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះតំបន់នេះស្ទើរតែពុំមានឈើដែលមានតំលៃពាណិជ្ជកម្ម ហើយដីប្រមាណជា ៥០ភាគរយជាដីជាំទឹក និងមានដង់ស៊ីតេធំជាងតំបន់ដ៏ទៃទៀត។ ដោយសារក្រុមហ៊ុនមិនទាន់ចាប់ផ្តើមធ្វើអាជីវកម្ម អ្វីដែលជាកង្វល់របស់យើងថានៅពេលអនាគតពេលដែលក្រុមហ៊ុនធ្វើអាជីវកម្ម តើដំណើរការធ្វើអាជីវកម្មរ៉ែមាសនៅក្នុងតំបន់នឹងវាប៉ះពាល់ទៅដល់គុណភាពទឹកស្រទាប់លើ និងគុណភាពទឹកស្រទាប់ក្រោមយ៉ាងដូចម្តេច? ដូចនេះក្រុមការងារ ហ្គ្រីន បានយកសំណាកទឹក



Draft

០២កន្លែងគឺ (១) ទឹកអូរ និង (២)ទឹកស្រះ ដែលស្ថិតនៅក្បែរការដ្ឋានក្រុមហ៊ុន ដើម្បីបង្ហាញពីគុណភាពទឹកស្រទាប់លើ និងគុណភាពទឹកស្រទាប់ក្រោម។

នៅពេលដែលក្រុមហ៊ុនចាប់ផ្តើមធ្វើអាជីវកម្ម នៅលើសន្និធិរ៉ែ មាសសរុប ៤០០,០០០ តោន ក្រុមហ៊ុនគ្រោងធ្វើអាជីវកម្មរយៈពេល ១០ឆ្នាំ ដូច្នេះផលប្រយោជន៍ ក្នុងការយកសំណាកទឹកដើម្បីយើងធ្វើ Monitoring បានន័យថា ជាសូចនាករមួយសំរាប់យើងត្រួតពិនិត្យរយៈពេលវែង ពីព្រោះការយកអាជីវកម្មរ៉ែនៅក្នុងតំបន់នេះមិនថាបើកគំរបព្រៃ ឬការលុងរណ្តៅដើម្បីតាមខ្សែរ៉ែទេ ក្រោយពីយករ៉ែមាសហើយយើងត្រូវកិនលំអិតអោយខ្ទេច រួចយើងប្រើសារធាតុគីមីដកយករ៉ែសុទ្ធ ដូច្នេះនៅក្នុងវិធីសាស្ត្រនៃការយករ៉ែមាស មួយជំហានបន្ទាប់មកទៀត។ ក្រុមហ៊ុននឹងដាក់ផែនការធ្វើអាជីវកម្មផលិតកម្មរ៉ែមាសអោយលំអិតមកក្រុមហ៊ុន ហ្វ្រីន ដើម្បីយើងពិនិត្យមើលថា តើវិធីសាស្ត្រនៃការដកយករ៉ែមាសសុទ្ធយ៉ាងម៉េច? ប៉ុន្តែចំណុចនេះខ្ញុំសូមបន្ថែមបន្តិច ជារួមបច្ចុប្បន្នយើងប្រើអាស៊ីដស្យាំណែត ដើម្បីដកយករ៉ែមាសចេញពីរ៉ែផ្សេងៗ ហើយក្រៅពីការយក អាស៊ីដស្យាំណែត ប្រសិនបើសន្និធិរ៉ែនៅក្នុងតំបន់នេះធំគឺគេប្រើវិធីសាស្ត្រមួយទៀត ដោយប្រើចរន្តអគ្គិសនីដែលមានតង់ស្យុងខ្ពស់ ដូច្នេះវាបង្កើតទៅជាកំលាំងម៉ាញេទិចមួយ នៅពេលដែលរ៉ែកិនម៉ត់ហើយពេលដែលគេបើកចរន្តធ្វើអោយកំលាំងម៉ាញេទិចទាញយកតែមាសសុទ្ធចេញមក ប៉ុន្តែការវិនិយោគបែបនេះគឺវាចំណាយទុនច្រើន។ ពាក់ព័ន្ធនឹងកំហាប់រ៉ែមាសនៅក្នុងតំបន់នេះ ១,៨៥ មីលីក្រាមនៅក្នុងរ៉ែមាសមួយតោន ប្រសិនយើងមើលទៅលើកិរិតបាត់បង់ផ្សេងៗការគណនារបស់ក្រុមហ៊ុនគឺមានប្រមាណតែ ៦៦ គីឡូប៉ុណ្ណោះ ដូច្នេះបរិមាណ មាសវាតិច មិនអាចអោយក្រុមហ៊ុនប្រើវិធីសាស្ត្រចំរាញ់យករ៉ែមាសអ្វីក្រៅពីអាស៊ីដស្យាំណែត ក្រៅតែពីការយកសំណាកទឹកយើងបានយកសំណាកដី ហើយសំណាកទឹកបានបញ្ជូនទៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ចំណែកឯ សំណាកដីបញ្ជូនទៅមន្ទីរពិសោធន៍របស់ក្រសួងកសិកម្ម ដើម្បីធ្វើការកត់ត្រាទុកថា តើនៅពេលដែលដំណើរការគុណភាពទឹក និងលក្ខណៈគ្រឿងគីមីរបស់ដីនៅក្នុងតំបន់នោះមានការប្រែប្រួលយ៉ាងដូចម្តេច?

បើតាមការបញ្ជាក់ពីសំណាក់លោកអភិបាលស្រុក ដីតំបន់នេះពុំមានជាប់ពាក់ព័ន្ធនឹងប្រជាជនដែលរស់នៅក្នុងឃុំរម្យទមទេ។ ឃុំរម្យទម មានប្រជាជនសរុបចំនួន ៩៣៧គ្រួសារ ស្មើនឹង ៤៣៤៧នាក់ ក្នុងនោះមានស្ត្រីចំនួន ១៨៧១នាក់ រស់នៅក្នុងភូមិចំនួន ០៦គឺ (១) ភូមិត្រពាំងទន្ទឹម (២) ភូមិទួលវវៀង (៣) ភូមិអូរទ្រលោក (៤) ភូមិបង្កើនផល (៥) ភូមិស្វាយដំណាក់ថ្មី និង (៦) ភូមិស្វាយដំណាក់ចាស់ ការរស់នៅនិងការប្រកបមុខរបរប្រជាជនតាមភូមិនៃឃុំទាំងនេះ មិនជាប់ពាក់ព័ន្ធនឹងដីសម្បទានរ៉ែមាសនេះទេ។ បើតាមអះអាងរបស់សហការីខ្ញុំគឺប្រជាជនគាត់ជីករ៉ែនៅតែរដូវវស្សាទេ ព្រោះមានទឹកលាងរ៉ែដល់ពេលរដូវប្រាំង គាត់នាំគ្នាចេញមកវិញ។ ការតាំងទីលំនៅ តាមសងខាងនៃបណ្តោយផ្លូវជាតិលេខ ៦២ និងតាមផ្លូវបំបែកទៅកាន់ភូមិស្វាយដំណាក់ចាស់ និងស្វាយដំណាក់ថ្មីជាលក្ខណៈប្រមូលផ្តុំនៅតាមភូមិ ហើយប្រជាជនភាគច្រើនជាជន

ជាតិកួយប្រមាណជា ៩០ភាគរយ ក្រៅពីនេះសុទ្ធតែជនជាតិខ្មែរ ចំណែក សំណង់ប្រាសាទប្រវត្តិសាស្ត្រមិនមានវត្តមានទេ។

នៅក្នុងការស្រាវជ្រាវ និងរុករករ៉ែមាស ដើម្បីឈានទៅធ្វើអាជីវកម្មតាមឯកសាររបស់ក្រុមហ៊ុន មានវិស្វករបរទេស ០៥នាក់ កម្មករបរទេស៣០នាក់ អ្នកស្គាល់ភូមិសាស្ត្រមូលដ្ឋាន ០១នាក់ កំលាំងសន្តិសុខ ១៥នាក់ និងអ្នកជំនួ ០៣នាក់ ហើយប្រើប្រាស់ម៉ាស៊ីនខួងរ៉ែ ០២គ្រឿង គ្រឿងចក្រសំរាប់កាយដី ០១គ្រឿង ម៉ាស៊ីនភ្លើង ០៣គ្រឿង និងម៉ាស៊ីន ០៤គ្រឿងកំលាំង ១៨សេស។ រយៈពេលនៃការស្រាវជ្រាវមានពីរដំណាក់កាលគឺ (១) ពីឆ្នាំ ២០០២ រហូតដល់ ខែសីហា ឆ្នាំ ២០០៥ (រយៈពេល ០៣ឆ្នាំ) និង(២) ពីខែ តុលា ឆ្នាំ ២០០៩ រហូតមកទល់នឹងបច្ចុប្បន្ន គឺលទ្ធផលនៃការសិក្សាស្រាវជ្រាវរ៉ែនៅក្នុងតំបន់នឹងមាន ៤០០,០០០ តោន តែជាមធ្យមមួយតោនមានមាស ១,៨៥ មីលីក្រាម ដូចនេះរ៉ែមាសសរុបប្រមាណ ៤០០,០០០ តោន ត្រូវប្រើប្រាស់ពេលវេលាជិត ១០ឆ្នាំ។ ដោយសារតែការវាយតំលៃជំហ៊ានដំបូងនេះ អ្វីដែលកើតមានឡើងដោយសកម្មភាពរុករករ៉ែ និយាយដោយឡែក ក្នុងករណីក្រុមហ៊ុន **ដែលខុម** គឺមានតិចតួច ដូចខ្ញុំបានជំរាបពីខាងដើម ទោះបីក្រុមហ៊ុនទទួលបានដីសម្បទានសរុប ១០០ហិកតា ទីតាំងដែលក្រុមហ៊ុនរៀបចំ ធ្វើទីស្នាក់ការប្រើប្រាស់តែ ២ហិកតាទេ ដូច្នេះអ្វីដែលកើតមានឡើងដោយការកាប់សំអាតព្រៃ ដើម្បីរៀបចំទៅជាទីស្នាក់នេះមានទំហំប្រមាណតែ២ហិកតាប៉ុណ្ណោះ។ ដូច្នេះនៅពេលអនាគតរយៈពេល ១០ឆ្នាំសំរាប់ធ្វើអាជីវកម្មរ៉ែមិនជាបញ្ហាដែរ ពីព្រោះវិធីសាស្ត្រនៃការយករ៉ែមាសមានពីរគឺ (១) ការបើកគំរបព្រៃហើយបើករណ្តៅដើម្បីជីកយករ៉ែ និង (២) ការជីកអន្លង់ចុះទៅក្រោមត្រង់ទៅដល់ជំរៅនៃរ៉ែ រួចជីកទៅតាមខ្សែរ៉ែ ឧទាហរណ៍ខ្សែរ៉ែខ្លះលើសបីម៉ែត្រ គឺគេលុងតែប៉ុណ្ណោះទេបើខ្សែរ៉ែទៅដល់ណាគាត់ លុងទៅដល់ហ្នឹង។ ដោយសារតែរណ្តៅរ៉ែមានលក្ខណៈជាការជីកលុង ដូចនេះការប្រើប្រាស់នៅខាងក្រោមវាមិនមានការកាប់ព្រៃឈើទេ កាលណាយើងឈូសឆាយព្រៃវាពាក់ព័ន្ធនឹងការហូរច្រោះ ដូច្នេះការរំខានដោយការប្រើប្រាស់ដីដោយសារការបើកគំរបព្រៃគឺពុំមានទេ លើកលែងតែនៅដំណាក់កាលស្រាវជ្រាវដែលគាត់ត្រូវការចាំបាច់សំរាប់សាងសង់ទីស្នាក់ការតែប៉ុណ្ណោះ។

ការធ្វើអាជីវកម្មនេះទៅអនាគតជាលក្ខណៈជីករណ្តៅលុងដែរ ដូចនេះការបិទរណ្តៅ និងការដាំព្រៃឡើងវិញក៏អត់មានលក្ខណៈដូចរ៉ែដទៃទៀតដែរ ខ្ញុំឧទាហរណ៍ដូចក្រុមហ៊ុន **សំណាងរ៉ែ** នៅស្រុកថ្មបាំង ខេត្តកោះកុង គាត់គ្រោងធ្វើអាជីវកម្មទៅលើរ៉ែអ៊ីលម៉េនីត មានលក្ខណៈជាបើកគំរបព្រៃដើម្បីជីកយករ៉ែនៅលើផ្ទៃដីសរុប ៥៣ហិកតាក្នុងមួយឆ្នាំ ដូច្នេះដើម្បីចូលទៅឆ្នាំទីពីរគាត់ត្រូវលុបរណ្តៅដែលគាត់បាននៅឆ្នាំទី១ ហើយធម្មតាដល់ពេលយើងជីកយករ៉ែនឹងចំរាញ់រួច បរិមាណសាច់ដីដែលជីកចេញ លុបទៅវិញអត់ដែលជិតទេ គឺនៅសល់ប្រមាណជា ២៥-៣០ភាគរយ នេះដែលជាបញ្ហា។ ចំណែកឯ ការជីកយក រ៉ែរបស់ក្រុមហ៊ុន **ដែល**

Draft

**ខុម (កម្ពុជា)** ទៅលើបរិមាណសរុបប្រមាណជា ៤០០,០០០ តោន អញ្ចឹងវាអត់មាន បញ្ហាអ្វីទាំងអស់ ដោយសារជីកនៅខាងក្រោម ដល់ពេលដែលធ្វើចប់ការបិទរណ្តៅនេះមិនមែនជាការបញ្ចូលសាច់ដីទេ ជាទូទៅ ប្រសិនជាអត់មានរន្ធច្រើនគេធ្វើរបងព័ទ្ធជុំវិញរន្ធរ៉ែតែម្តង។ ការបិទរណ្តៅរ៉ែយូរឆ្នាំធ្វើអោយស្មៅដុះស៊ុបទ្រុប ជូនកាលប្រជាជននៅក្នុងតំបន់គាត់ទៅរកនេះរកនោះអាចធ្លាក់ ឬក៏សត្វព្រៃធ្លាក់ ដូច្នេះវិធីសាស្ត្រដើម្បីកាត់បន្ថយប៉ះពាល់នឹងគេធ្វើរបងព័ទ្ធជុំវិញ។ មួយទៀតប្រសិនបើរណ្តៅរ៉ែវាញឹកជាប់គ្នាគេប្រើម្សៅស្បាណែតបំផុះរន្ធតែម្តង ដល់ពេលបំផុះរន្ធសាច់ដីវាបាក់ស្រុតចុះដល់ពេលប្រជាជនគាត់ដើរមក ឃើញរណ្តៅគាត់អាចដើរជៀស នេះជាវិធីសាស្ត្រដើម្បីទប់ស្កាត់នៅក្នុងបិទរណ្តៅរ៉ែផងដែរ។ បន្ទាប់មកទៀតមើលទៅផលប៉ះពាល់សំលេង និងការបំភាយឧស្ម័នកាបូនិច និងសារធាតុពុល នេះវាកើតមានឡើងដោយសារការប្រើប្រាស់គ្រឿងចក្រ នៅក្នុងតំបន់គំរោងគ្រឿងចក្រដែលត្រូវប្រើប្រាស់គឺមានតែម៉ាស៊ីនភ្លើងទេ ដោយសារតំបន់នឹងស្ថិតនៅឆ្ងាយពីតំបន់ដែលប្រជាជនរស់នៅប៉ះពាល់ដែលដែលកើតឡើងជាផលប៉ះពាល់បន្ទាប់បន្សំ ហើយឧស្ម័នកាបូនិចដែលបំភាយឡើងដោយចំហេះប្រេងឥន្ធនៈទាំងអស់ក៏មិនមែនជាបញ្ហាដែរ។ ការបាត់បង់ទីជំរកក៏មានលក្ខណៈដូចទៅនឹងការបកស្រាយខាងលើ ដោយសារតែក្រុមហ៊ុនគ្មានផែនការឈូសស្រទាប់ព្រៃដើម្បីជីកយករ៉ែមាស ដូច្នេះការកើតមានដោយសារវត្តមានរបស់មនុស្ស និងសំលេងម៉ាស៊ីនភ្លើងនៅក្នុងតំបន់នឹង ដូចជាសត្វព្រៃដែលពីមុនមកវាធ្លាប់ឆ្លងកាត់កន្លែងហ្នឹងវាអាចដើរជៀសនៅក្បែរៗហ្នឹង ដោយសារដីធ្វើអាជីវកម្មរ៉ែមាសមានទំហំតែ ១០០ ហិកតា ដូច្នេះវាមិនមែនជាបញ្ហា។ ខ្ញុំសូមសង្ខេប នៅដំណាក់កាលបន្ទាប់ទៀត នៅពេលដែលក្រុមហ៊ុនដំណើរការអាជីវកម្មក្រសួងបរិស្ថាននឹងទាមទារអោយមានការវាយតំលៃម្តងទៀត ដែលអោយឈ្មោះថា ការវាយតំលៃជាលក្ខណៈពេញលេញ ទើបតំរូវអោយខ្ញុំបកស្រាយលំអិត។

ឯកឧត្តម **ស៊ុយ សេរិទ្ធ** អភិបាលរងខេត្តព្រះវិហារ : សូមអរគុណចំពោះតំណាងក្រុមហ៊ុនដែលបានធ្វើបទបង្ហាញយ៉ាងក្បោះក្បាយ ក្រុមហ៊ុនដែលមករុករករ៉ែនៅក្នុងខេត្តយើងនេះមានទាំងអស់ចំនួន ២៣ក្រុមហ៊ុន ប៉ុន្តែមិនទាន់ដែលមានក្រុមហ៊ុនណាយកលទ្ធផលមកធ្វើបទបង្ហាញដូចក្រុមហ៊ុន Delcom (Kampuchea) PTE. LTD.ទេ។ នេះជាបទបង្ហាញមួយដែលអោយអាជ្ញាធរដែនដី និងមន្ទីរពាក់ព័ន្ធបានដឹងដើម្បីពិភាក្សាគ្នា និងដោះស្រាយពីបញ្ហាប្រជាពលរដ្ឋ និងបរិស្ថានព្រៃឈើដែលនៅតំបន់នោះ ហើយនេះគ្រាន់តែជាការសិក្សាដំបូង ហើយដីដែលក្រុមហ៊ុនស្រាវជ្រាវរុករករ៉ែមានទំហំ ១០០ហិកតា និងប្រើប្រាស់ដីសាងសង់ទីស្នាក់ការប្រមាណជា ២ហិកតាតែប៉ុណ្ណោះ។ ចំណែកឯ ផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានកាលណាយើងធ្វើការអភិវឌ្ឍន៍តែងតែមានផលប៉ះពាល់ជៀសមិនផុត ប៉ុន្តែបើតាមការធ្វើបទបង្ហាញមិនជាប៉ះពាល់ប៉ុន្មានទេនៅតំបន់នោះ ដូច្នេះដើម្បីអោយមន្ទីរជំនាញមានការចូលរួមនៅក្នុងការងារនេះ ដំបូងខ្ញុំសូម

Draft

អញ្ជើញមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាសេនាធិការអោយក្រសួងឧស្សាហកម្មដែលនៅ ក្នុងជួរថ្នាក់ខេត្តមានមតិយោបល់លើគំរោងវិនិយោគរបស់ក្រុមហ៊ុន។

លោក **ស្រំ ណរងឺ** ប្រធានមន្ទីរឧស្សាហកម្មខេត្តៈ តាមរបាយការណ៍តំណាងក្រុមហ៊ុន បានធ្វើបទបង្ហាញកន្លងមកនេះក្រុមហ៊ុន Delcom (Kampuchea) PTE. LTD. ជាក្រុមហ៊ុនមួយដែលមានលក្ខណៈស្របច្បាប់ដូចដែលបានរាយការណ៍ជូនក្នុងអង្គប្រជុំអម្បាញ់មិញ។ លទ្ធផលនៃការសិក្សាកន្លងមកនេះដែលខ្ញុំបានទទួល សូមរាយការណ៍អោយអង្គប្រជុំបានជ្រាបនៅពេលនេះ។ ដោយសារភូមិសាស្ត្រក្រុមហ៊ុន Delcom (Kampuchea) PTE. LTD. មានទំហំ ១០០ ហិកតា តូចជាងក្រុមហ៊ុនដទៃទៀតដែលមានអាជ្ញាប័ណ្ណធ្វើការសិក្សានៅក្នុងខេត្តព្រះវិហារកន្លងមក ហើយភូមិសាស្ត្ររបស់ក្រុមហ៊ុននេះស្ថិតនៅក្នុងការហ៊ុំព័ទ្ធរបស់ក្រុមហ៊ុន **ស៊ីយូអេស** ដែលធ្វើការសិក្សាស្រាវជ្រាវរ៉ែដែកនៅទីនោះ។ បើយើងពិនិត្យទីតាំងរបស់ក្រុមហ៊ុនគឺគ្របដណ្តប់ទៅដោយព្រៃល្បោះ និងព្រៃពាក់កណ្តាលស្រោង ដូចដែលតំណាងក្រុមហ៊ុនបានរាយការណ៍ជូន ដូច្នេះខ្ញុំសូមអោយខាងមន្ទីរពាក់ពន្ធ័ដូចជាៈ រដ្ឋបាលព្រៃឈើ មន្ទីរបរិស្ថាន និងមន្ទីរកសិកម្មធ្វើការចាប់អារម្មណ៍ ពីព្រោះផ្ទៃដីដែលត្រូវធ្វើការយករ៉ែមាសវាជាការបើករណ្តៅ ដើម្បីយករ៉ែនៅខាងក្រោម ដូច្នេះផលប៉ះពាល់គឺមានតិចតួច ណាមួយវាស្ថិតនៅឆ្ងាយពីភូមិរបស់រស់នៅប្រជាជនទៀត។ ដូចេះខ្ញុំគ្រាន់តែសំណូមពរទៅក្រុមហ៊ុនចាប់ពីពេលនេះទៅសូមអោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរ និងពេលមានហេតុការណ៍អ្វីកើតឡើង សូមផ្តល់ពតិមានអោយមន្ទីរបានដឹងផង ពីព្រោះកន្លងទៅនៅដើមឆ្នាំនេះមានបាតុភាពកើនឡើងច្រើនលើកច្រើនសារហើយ។

ឯកឧត្តម **ស៊ុយ សេរិទ្ឋ** អភិបាលរងខេត្តព្រះវិហារៈ សូមអរគុណមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ដែលសូមអោយក្រុមហ៊ុនធ្វើការសហការយ៉ាងជិតស្និទ្ធជាថ្នាក់ខេត្ត និងមន្ទីរ ដើម្បីអោយដំណើរទៅយ៉ាងរលូន ហើយបន្ថមកទៀតការចូលរួមពីមន្ទីរបរិស្ថាន និង រដ្ឋបាលព្រៃឈើ ដែលតំបន់នោះប៉ះពាល់បរិស្ថានទាំងវិជ្ជមាន និងអវិជ្ជមានយ៉ាងម៉េច? សូមអោយខាងបរិស្ថានលើឡើង និងបន្ទាប់រដ្ឋបាលព្រៃឈើ។

លោក **ខូយ ឃុនរដ្ឋ** ប្រធានមន្ទីរបរិស្ថានខេត្តៈ ខ្ញុំសូមអរគុណដែលក្រុមហ៊ុនបានធ្វើបទបង្ហាញរបាយការណ៍វាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមដំបូង ទៅលើការសិក្សាស្រាវជ្រាវរុករករ៉ែមាសរបស់ក្រុមហ៊ុន Delcom (Kampuchea) PTE.LTD មានទំហំ ១០០ហិកតា ស្ថិតក្នុងឃុំរម្យទម ស្រុករវៀងខេត្តព្រះវិហារ។ ទាក់ទងទៅនឹងឯកសារ និងរបាយការណ៍ក្តីមន្ទីរខ្ញុំទើបតែបានដឹងនៅពេលនេះតែប៉ុណ្ណោះព្រោះខ្ញុំមិនមានឯកសារអ្វីដើម្បីពិនិត្យលើរបាយការណ៍នេះទេ ម្យ៉ាងទៀតពាក់ពន្ធ័ទៅនឹងរបាយការណ៍ វាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ ទើបតែមានបទបង្ហាញនៅពេលនេះ ប៉ុន្តែយើងឃើញថារបាយការណ៍វាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមដំបូង នេះឃើញថាមានភាពលំអិតល្អ។ ប៉ុន្តែបើយើងផ្អែក

Draft

ទៅលើសកម្មភាពមួយដែលអនុវត្តទៅតាមច្បាប់ដែលបានកំណត់រួចហើយ នៅពេលខាងមុខនេះការវាយតំលៃផលប៉ះពាល់ពេញលេញមួយទៀតដែលអនុវត្តន៏ទៅតាមអនុក្រិតលេខ ៧២ ដោយសារអនុក្រិតនេះមានចែកនៅក្នុងឧបសម្ព័ន្ធ ការពិនិត្យការវាយតំលៃផលប៉ះពាល់បរិស្ថានទាំងដំបូង និងពេញលេញជាដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដូច្នេះមន្ទីរបរិស្ថានខេត្តជាអង្គភាពដែលមិនមាន លទ្ធភាពក្នុងការពិនិត្យទៅលើរបាយការណ៍នេះទេ វាជាការអង្កេត និងពិនិត្យរបស់ក្រសួងបរិស្ថាន។ ដូច្នេះ ខ្ញុំគ្រាន់តែផ្តល់ជាគំនិតសូមអោយក្រុមហ៊ុន Delcom (Kampuchea) PTE.LTD ផ្តល់នូវផែនទី និងឯកសារដែលពាក់ពន្ធ័ ជាពិសេសរបាយការណ៏វាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ ពីព្រោះខ្ញុំទើបតែបានទទួលពតិមាននៅថ្ងៃនេះតែប៉ុណ្ណោះ។ ដូច្នេះការផ្តល់យោបល់អ្វីយើងមិនអាចនិយាយទៅហើយមានការបកក្រោយបានទេ ការងារបច្ចេកទេសត្រូវការលំអិតបន្តិច និងមានភាពច្បាស់លាស់ ពិតមែនវាមិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់មន្ទីរ ក៏ប៉ុន្តែជាទូទៅនៅពេលដែលក្រុមហ៊ុនអនុវត្តន៏អ្នកដែលនៅផ្ទាល់ក្នុងមូលដ្ឋាននេះហើយជាអ្នកត្រួតពិនិត្យ។ ករណីមួយទៀតសូមអោយក្រុមហ៊ុនធ្វើការសហការជាមួយមន្ទីរអោយបានជិតស្និទ្ធ ដើម្បីកុំអោយការសហការរបស់យើងមានភាពមិនចុះសម្រុងគ្នា ប្រសិនជាយើងទប់ស្កាត់មុនវាជាការល្អជាងអ្វីដែលបង្កើតបញ្ហា ទើបយើងដោះស្រាយនេះ ជាចំណាប់អារម្មណ៏របស់ខ្ញុំ។ ម្យ៉ាងទៀតបើពិនិត្យទៅលើផែនទី និងនិយាមកានៃរបាយការណ៏នេះឃើញថា តំបន់នេះស្ថិតនៅក្នុងគំរបព្រៃ ១០០ភាគរយ និងសំបូរទៅដោយអាងធម្មជាតិជាច្រើន វាពិតមែនថានៅតំបន់នេះសំបូរដែអូរតូចៗ បើនិយាយតំបន់នៅប៉ែកខាងកើតគឺមានប្រភពធំមួយហៅថា ស្ទឹងសែន បើនិយាយពីប៉ែកខាងលិចគឺមានប្រភពទឹកស្ទឹងស្មោង ដូច្នេះតំបន់នេះតំបន់ទីជំរាលដែលពាក់ពន្ធ័ទៅនឹងប្រភពទឹកទាំងអស់នេះ ប៉ុន្តែដោយសារទំរង់នៃការធ្វើអាជីវកម្មស្រាវជ្រាវរុករករ៉ែមាសមានទំហំតូច ដូចនេះផលប៉ះពាល់ពុំមានអ្វីធ្ងន់ធ្ងរទេ។ បើក្រុមហ៊ុនយករ៉ែមាសទាំងអស់ចេញមកពីក្នុងដីហើយយកទៅបំបែកដើម្បីទាញយកមាសសុទ្ធ ប្រសិនក្រុមហ៊ុនប្រើប្រាស់ចរន្តអគ្គិសនីផលប៉ះពាល់ស្ទើរតែគ្មាន ប៉ុន្តែបើក្រុមហ៊ុនប្រើសារធាតុគីមីផ្សេងៗវាអាចនឹងមានផលប៉ះពាល់ ដូច្នេះក្រុមហ៊ុនត្រូវមានផែនការការពារជាមុន ដើម្បីផលប៉ះពាល់នេះវាមិនកើតមានឡើងចំពោះសាធារណៈ។

លោក **នន ខេមរិន្ទ** នាយរងរដ្ឋបាលព្រៃឈើ : ខ្ញុំសូមកោតសរសើរការធ្វើបទបង្ហាញ របាយការណ៏វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង របស់ក្រុមហ៊ុន ដែល ខុម (កម្ពុជា) ភីធីអ៊ី ប៉ុន្តែការលើកឡើងនេះគ្រាន់តែជាហានិភ័យដែលគិតមិនទាន់បានធ្វើនៅឡើយ។ ទី (១) បញ្ហាអាចម៏ដីដែលយកចេញពីណ្តៅរ៉ែពេលយើងយកចាក់រាយប៉ាយក៏វាមានផលប៉ះពាល់ដែរ ទី (២) ការលុបរណ្តៅមិនបានជិតល្អ ប៉ុន្តែបើតាមច្បាប់ព្រៃឈើរាល់អ្វី ដែលបានធ្វើហើយត្រូវតែសំអាតដាំដើមឈើឡើងវិញ។ ចំពោះរាល់ការធ្វើអាជីវកម្ម

រ៉ែខ្ញុំមិនទាន់ដឹងថា ក្រុមហ៊ុនបានទាក់ទងជាមួយក្រសួងកសិកម្ម ឬនៅទេ បើមិនទាន់សូមបំពេញបែបបទអោយបានត្រឹមត្រូវ។

លោក **ពឹង ឡូឌា** ប្រធានមន្ទីរកសិកម្មខេត្តៈ ចំពោះគំរោងសិក្សាស្រាវជ្រាវ និងរុករករ៉ែមាសនេះស្ថិតនៅឃុំរម្យទមដែលជាឃុំខ្ញុំបាទកាន់ផ្ទាល់ ហើយប្រជាជនដែលរស់នៅក្នុងឃុំនេះភាគច្រើនជាជនជាតិកួយ។ ខ្ញុំសូមអោយជំនាញខាងវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គម ធ្វើការពិភាក្សាជាមួយក្រុមហ៊ុនធ្វើយ៉ាងកុំអោយមានផលប៉ះពាល់ដល់ប្រជាជន ព្រោះកន្លងមកមានប៉ះពាល់ដល់សតិអារម្មណ៍របស់ពួកគាត់លើសពីនេះទៅទៀត ថែមទាំងមានសារពតិមានមួយចំនួនបានចុះផ្សាយទាក់ទងនឹងប្រជាជនក្នុងឃុំរម្យទមតែម្តង។ ដូច្នេះអ្វីដែលយើងលើកឡើងនេះពាក់ពន្ធ័នឹងផលប៉ះពាល់បរិស្ថាន ដូចជាជាក់ស្តែងកន្លងមកការប្រើបច្ចេកទេសមិនបានទៅតាមបទដ្ឋានបច្ចេកទេស ធ្វើអោយកាកសំណល់ដែលនៅគរទុក បង្កអោយមានការកកស្ទះដល់ប្រភពទឹកដែលប្រជាជនប្រើប្រាស់នៅក្នុងតំបន់នោះ។ ដូច្នេះខ្ញុំសូមអោយក្រុមហ៊ុនដែលធ្វើការរុករករ៉ែមាសនៅតំបន់នោះធ្វើយ៉ាងណាគិតគូរទៅលើកាកសំណល់ដែលនៅសល់ក្រោយពីការឈូសឆាយរួច ដើម្បីកុំអោយមានផលប៉ះពាល់បរិស្ថាន និងប្រជាជនសហគមន៍។

លោក **ង៉ា សារ៉ូ** អភិបាលស្រុករវៀងៈ ទាក់ទងទៅនឹងផលប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ដែលខុម (កម្ពុជា) ភីធីអ៊ី នៅក្នុងទីតាំងនេះខ្ញុំបានចុះទៅពិនិត្យមានការញ៉ឹកញ៉ាប់ដែររួមជាមួយមន្ទីរឧស្សាហកម្ម និងថ្នាក់ដឹកនាំខេត្ត។ ទិដ្ឋភាពជាក់ស្តែងនៅតំបន់នោះទាក់ទងទៅនឹងទីតាំង ដូចជាមិនមានបញ្ហាអ្វីចោទទេទៅលើផលប៉ះពាល់ព្រៃឈើ ព្រោះក្រុមហ៊ុនប្រើប្រាស់ដីប្រមាណជា ២ហិកតាតែប៉ុណ្ណោះ សំរាប់សាងសង់ទីស្នាក់ការ ហើយទីតាំងនេះស្ថិតនៅតាមបណ្តោយជើងភ្នំ និងមានទីជំរាលដោយកន្លែងដែលដាក់គ្រឿងចក្រ ក៏ដូចជារណ្តៅដែលក្រុមហ៊ុនធ្វើការសិក្សាស្រាវជ្រាវមិនមានផលប៉ះពាល់អ្វីធំដុំទេ ផ្ទៃដីដែលក្រុមហ៊ុនធ្វើអាជីវកម្មមានទំហំ ១០០ហិកតា តែជាក់ស្តែងឃើញប្រើប្រាស់ដីប្រមាណជា ២ហិកតាទេ។ ចំពោះផលប៉ះពាល់ផ្សេងទៀត ដែលជះឥទ្ធិពលពីការប្រើប្រាស់សារធាតុ និងកាកសំណល់ផ្សេងៗដែលហូរចូលប្រពន្ធ័អូរយើងត្រូវធ្វើការទប់ស្កាត់យ៉ាងម៉េចកុំអោយមាន។ ចំណែកឯ ផលប៉ះពាល់សង្គមតាមខ្ញុំពិនិត្យមើលឃើញថា នៅឆ្ងាយពីទីតាំងដែលប្រជាជនរស់នៅ តែមានភូមិមួយគឺភូមិរំដេងមានប្រមាណជា ២០-៣០គ្រួសារ ដែលប្រជាជន ប្រកបមុខរបរធ្វើស្រែ-ចំការតិចតួច និងជីកមាស ប៉ុន្តែវាមិនស្ថិតនៅឆ្ងាយពីទីតាំងក្រុមហ៊ុន ៥គីឡូម៉ែត្រ ដូច្នេះទាក់ទងនឹងការប្រកបមុខរបររបស់ប្រជាជនក្នុងឃុំរម្យទមនេះដូចជាមិនមានផលប៉ះពាល់អ្វីទេ មានតែភូមិរំដេងមួយទេ ហើយភូមិនេះមិនទាន់ជាផ្លូវនៅឡើយ ភូមិនេះកើតឡើងដោយសារប្រជាជននាំគ្នាទៅជីកមាសហើយបង្កើតជាផ្ទះ នៅពេលអនាគតវាអាចក្លាយទៅជាភូមិមួយដែលស្របច្បាប់ ព្រោះកាន់តែរីកទៅៗ កាលណាប្រជាជនរស់នៅទីនោះច្រើនផលប៉ះពាល់ជាមួយក្រុមហ៊ុននឹងកើតមាន ប៉ុន្តែទិដ្ឋភាពជាក់

Draft

ស្តែងមិនទាន់ប៉ះពាល់ទេ។ ចំពោះប្រជាជនដែលរស់នៅក្នុងឃុំរម្យទមភាគច្រើនជាជនជាតិកួយ មានប្រមាណជា៩០ភាគរយ ហើយពួកគាត់បើជឿក៏ជឿខ្លាំង បើស្អប់ក៏ស្អប់ខ្លាំង ដូច្នេះពួកឱកាសនិយមឈ្លៀតឱកាសយកផលចំណេញពីពួកគាត់ ហើយរឿងដែលកើតឡើងដោយ អាស៊ីសេរី វីអូអេ និងកាសែតចុះផ្សាយមិនមែនរឿងក្រុមហ៊ុន ដែល ខុម (កម្ពុជា)ទេ មានរឿងផ្សេងទៀត។ នៅពេលអនាគតបើសិនជាក្រុមហ៊ុនធ្វើអាជីវ-កម្មពេញលេញ យើងត្រូវពិភាក្សាអោយលំអិត និងស៊ីជំរៅជាងនេះ ទី(១) ដោះស្រាយអំពីផលប៉ះពាល់បរិស្ថាន និងទី(២) ដោះស្រាយពីសតិអារម្មណ៍របស់ប្រជាជន។

លោក **ខូយ ឃុនហ៊ា** នាយករដ្ឋបាលសាលាខេត្តៈ តាមរយៈការបង្ហាញរបស់ក្រុមហ៊ុន ហ្រ្គីន យើងឃើញថា វាទាក់ទងទាំងស្រុងទៅលើជំនាញបច្ចេកទេស ដែលមន្ទីរជំនាញពាក់ពន្ធ័បានលើកឡើងអស់ហើយ តាមទស្សនៈរបស់ខ្ញុំ ជាគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺអូសទាញការវិនិយោគគ្រប់ទីកន្លែង ហើយកន្លងមកនេះក៏ដូចជាឯកឧត្តមអភិបាលមុន នឹងឯកឧត្តមអភិបាលខេត្តបច្ចុប្បន្នតែងតែផ្សព្វផ្សាយគ្រប់ទីកន្លែងទាំងក្នុង និងក្រៅប្រទេសពីសក្តានុពលដែលមានក្នុងខេត្តព្រះវិហារដូចជាៈ រ៉ែ កសិកម្ម ទេសចរណ៍ ។ល។ ដូចនេះគោលបំណងរបស់ខេត្ត ចង់អោយមានការអភិវឌ្ឍន៍ដើម្បីទាញយកសក្តានុពលទាំងអស់នេះមកប្រើប្រាស់។ ជារួមខ្ញុំសូមស្វាគមន៍លើការសិក្សាស្រាវជ្រាវរុករករ៉ែរបស់ក្រុមហ៊ុន ដែល ខុម (កម្ពុជា) ភីធីអ៊ី. អិលធីឌី ប៉ុន្តែអ្វីដែលខ្ញុំមានការព្រួយបារម្ភនោះ ពេលដែលបានគោលការណ៍អនុញ្ញាតវិនិយោគពីរាជរដ្ឋាភិបាលទៅលើទីតាំងនោះ ដែលកន្លងមកនេះលោកប្រធានមន្ទីរកសិកម្ម និងលោកអភិបាលស្រុកបានលើកឡើងរួចហើយ ឃើញថា កន្លែងនោះសំបូរទៅដោយក្រុមប្រឆាំងនឹងរាជរដ្ឋាភិបាល ធ្វើយ៉ាងម៉េចកុំអោយក្រុមអ្នកប្រឆាំងមានចំណុចវាយបកមកលើរាជរដ្ឋាភិបាល។ នៅពេលដែលក្រុមហ៊ុនដំណើរទៅខ្វះខាតចន្លោះណាមួយមិនត្រឹមតែចាប់ចំនុចខ្សោយក្រុមហ៊ុនវាយទៅលើក្រុមហ៊ុនខ្លួនឯងទេ វាអាចវាយទៅលើរាជរដ្ឋាភិបាលតែម្តង ព្រោះរាជរដ្ឋាភិបាលជាអ្នកអនុញ្ញាតអោយក្រុមហ៊ុនធ្វើអាជីវកម្ម។ ជាចុងក្រោយខ្ញុំសូមអោយក្រុមហ៊ុនធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយនឹងគ្រប់សមត្ថកិច្ចទាំងអស់ដែលពាក់ពន្ធ័ ដើម្បីទប់ស្កាត់រាល់ហេតុការដែលកើតឡើងអោយបានទាន់ពេល។

ឯកឧត្តម **ស៊ុយ សេរិទ្ធ** អភិបាលរងខេត្តព្រះវិហារៈ ចំពោះខ្ញុំសូមអោយក្រុមហ៊ុន ហ្រ្គីន ធ្វើការពន្យល់ និងបកស្រាយនៅ ០៧ ចំនុចដែលខ្ញុំបានសង្ខេបនៅក្នុងអង្គប្រជុំគឺ (១) សុំអោយមានការសហការអោយជិតសិទ្ធយ៉ាងម៉េចកុំអោយមានបញ្ហាទៅថ្ងៃអនាគត (២) ត្រូវមានផែនការមេអោយបានច្បាស់លាស់ដើម្បីអោយអាជ្ញាធរបានដឹងពីគំរោងចាប់ផ្តើមពេលណាហើយបញ្ចប់ពេលណា (៣) សូមអោយលើអំពីវិធានការណ៍ទប់ស្កាត់ផលប៉ះពាល់ដែលកើតមានឡើង (៤) សូមធ្វើការទំនាក់ទំនងជាមួយក្រសួងកសិកម្ម ថាតើក្រុមហ៊ុនកន្លងមកបានធ្វើការជាមួយក្រសួងកសិកម្មខ្លះហើយ ឬនៅ ព្រោះទាក់ទងជាមួយព្រៃឈើ? (៥) សូម

អោយក្រុមហ៊ុនមុននឹងប្រើសារធាតុផ្ទុះត្រូវរាយការណ៍ទៅប៉ូលីសដើម្បីយើងជូនដំណឹងទៅមូលដ្ឋាន (៦) ក្រុមហ៊ុនត្រូវធ្វើយ៉ាងម៉េចអូសទាញជនជាតិភាគតិចអោយបានដើម្បីបំរើការសង្គម និងរាជរដ្ឋាភិបាលផងតាមរយៈការផ្តល់មូលនិធិសំរាប់ទ្រទ្រង់សហគមន៍ក្នុងតំបន់ ឬមួយយ៉ាងណា? និង (៧) សូមអោយទទួលស្គាល់អង្គភាពទីចាត់ការអន្តរវិស័យគាត់ធ្វើការតំណាងអោយឯកឧត្តមអភិបាលខេត្ត ដូច្នេះសូមធ្វើការអោយបានជិតស្និទ្ធជាមួយអង្គភាពនេះផង។

បណ្ឌិត **លី សុពណ៌-មុនី** នាយក GCF: ខ្ញុំសូមធ្វើការបំភ្លឺជូនទៅលើអង្គប្រជុំទាំងមូលដែលមានប្រាំពីរចំនុចដោយសង្ខេប ជាទូទៅដោយសារតែក្រុមហ៊ុន **ដែល ខុម (កម្ពុជា) ភីធីអ៊ី** ស្ថិតនៅក្នុងដំណាក់កាលស្រាវជ្រាវ ដូច្នេះនៅក្នុងដំណាក់កាលនឹងគាត់យកចិត្តទុកដាក់តែទៅលើបញ្ហាបច្ចេកទេសស្រាវជ្រាវដើម្បីឈានទៅបញ្ចប់ក្នុងការកំណត់ថា តើសន្និធិរ៉ែនៅក្នុងតំបន់នោះមានប៉ុន្មាន? ដើម្បីរៀបចំផែនការអាជីវកម្មហើយនៅក្នុងដំណើរផលិតកម្មរ៉ែមាសនេះ ខ្ញុំជឿជាក់ថាឯកឧត្តមប្រធានអង្គប្រជុំ និងមន្ទីរពាក់ពន្ធ័ទាំងអស់បានជ្រាបហើយក្នុងដំណើរការអាជីវកម្មមិនអាចក្រុមហ៊ុន **ដែល ខុម (កម្ពុជា) ភីធីអ៊ី អិលធីឌី.** គាត់ដំណើរការអាជីវកម្មដោយគ្មានការចូលរួមអំពីស្ថាប័នជំនាញនោះទេ ហើយមិនថាក្រុមហ៊ុន **ដែល ខុម (កម្ពុជា) ភីធីអ៊ី** ឬថាក្រុមហ៊ុនណាទេ នៅពេលដែលមានដំណើរការតែងតែសហការជាមួយអាជ្ញាធរមូលដ្ឋាន។ ចំនុចទី១ ខ្ញុំលើកឧទាហរណ៍ជាក់ស្តែងក្រុមហ៊ុន **ដែល ខុម (កម្ពុជា) ភីធីអ៊ី** បានប្រើប្រាស់សន្តិសុខចំនួន ១៥ នាក់ សន្តិសុខនេះគឺជាកំលាំងរបស់ខេត្តតែម្តង ហើយឯកសារផ្សេងៗក្រុមហ៊ុន ដែល ខុម (កម្ពុជា) ធ្វើការសហការជាមួយខេត្ត និងស្រុករួចហើយ។ រាល់អ្វីដែលស្រុកបានលើកឡើងគឺថាដំណើរការមកមានលក្ខណៈរលូនជាមួយគ្នា នេះការសហការគ្រាន់តែកិច្ចសហការទៅតាមជំហានៗទៅតាមដំណាក់កាល តើដំណាក់កាលស្រាវជ្រាវមានស្ថាប័នណាខ្លះចូលរួម ដល់ពេលធ្វើការដំណើរការតំរូវអោយមានអង្គភាពបច្ចេកទេសណាចូលរួម ដើម្បីបំពេញទៅតាមលក្ខណៈច្បាប់។ អង្គភាពមួយចំនួនជាពិសេសមន្ទីរបរិស្ថានគឺមានក្រុមការងារមួយដែលស្ថិតនៅក្នុងនាយកដ្ឋាន EIA គាត់ត្រូវចុះមកធ្វើការត្រួតពិនិត្យតាមដានវាយតំលៃជាប្រចាំ។ ចំនុចទី២ ដើម្បីឈានទៅដល់ដំណើរការអាជីវកម្មពេញលេញ ត្រូវមានការអនុញ្ញាតផ្សេងៗទៀតពីស្ថាបនពាក់ពន្ធ័ ឧទាហរណ៍ពាក់ពន្ធ័ទៅនឹងអាជ្ញាបណ្ណ័អាជីវកម្ម និងច្បាប់វិនិយោគខ្ញុំអត់ទាន់បានពិគ្រោះយោបល់ជាមួយក្រុមហ៊ុន ដែល ខុម (កម្ពុជា) នៅឡើយទេត្រង់ចំនុចនឹងតទៅក្រុមហ៊ុន ដែល ខុម (កម្ពុជា) ត្រូវនាំយកនូវគ្រឿងចក្រ បច្ចេកទេសមួយចំនួនទៀតមកបំរើការអាជីវកម្មនៅក្នុងតំបន់នេះ ដូច្នេះបើច្បាប់វិនិយោគគាត់ត្រូវឆ្លងទៅ CDC ដើម្បីមានច្បាប់វិនិយោគបានក្រុមហ៊ុនត្រូវមានរបាយការណ៍វាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមដំបូង។ ក្រោយពេលដែលខ្ញុំបានជួបពិគ្រោះយោបល់ជាមួយក្រុមហ៊ុនពិភាក្សាទៅលើឯកសារដែលក្រុមហ៊ុន ដែល ខុម

Draft

(កម្ពុជា) ត្រូវផ្តល់។ ដូច្នេះទើបយើងមិនធ្វើការវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញទេគឺធ្វើរបាយការណ៍វាយតំលៃដំបូង ទី១ ក្រុមហ៊ុនចំណាយថវិកាតិច និងទី២ ពេលវេលាលឿនទាន់សភាពការផង ។

ការធ្វើអាជីវកម្មទៅលើប្រភេទរ៉ែមាស ងាយនឹងបង្កការរងគ្រោះដល់បរិស្ថានធម្មជាតិដែលនៅជុំវិញនោះណាស់ អាស្រ័យហេតុនេះ បន្ទាប់ពីក្រុមហ៊ុនបានចាប់ផ្តើមដំណើរការអាជីវកម្មពេញលេញទៅលើប្រភេទរ៉ែមាសនេះហើយ ក្រុមហ៊ុនចាំបាច់ត្រូវធ្វើការវាយតំលៃបន្ថែមអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ទៅលើបញ្ហាមួយចំនួនដូចជា: (១) សិក្សាអំពីសម្ព័ន្ធគីមីសកម្ម (ប្រភេទ និងបរិមាណ) ដែលមាននៅលាយឡំជាមួយនឹងរ៉ែទាំងនោះ ពីព្រោះថាជាធម្មតាពួកលោហៈទាំងឡាយដែលមាននៅក្នុងធម្មជាតិ មិនដែលស្ថិតនៅជាអង្គធាតុទោលនោះទេ។ ដោយហេតុថា នៅក្នុងជំរករ៉ែមាសនេះពិនិត្យឃើញមានវត្តមានរបស់លោហៈផ្សេងៗទៀតមានដូចជា: ដែក ប្រាក់ ស្ពាន់ សំណរ...។ល។ ជាសន្និដ្ឋាន នៅក្នុងតំបន់នេះអាចនឹងមានពពួកសម្ព័ន្ធគីមីសកម្មផ្សេងៗទៀត ដែលអាចបង្កជាហេតុអាក្រក់ដល់មជ្ឈដ្ឋានជុំវិញ ប្រសិនបើផែនការអាជីវកម្មលើរ៉ែមាសនេះ មិនបានរៀបចំអោយត្រូវទៅតាមបទដ្ឋានបច្ចេកទេសនោះ។ (២) នៅក្នុងករណីដែលរ៉ែមាសនៅតំបន់នោះសម្បូរណ៍ទៅដោយសារធាតុ Sulfur នោះទឹកដែលហូរ (ជ្រាប)ចេញពីពំនូករ៉ែ ឬកន្លែងកាយរ៉ែអាចក្លាយទៅជាអាស៊ីដដែលមានកំហាប់ខ្ពស់។ ដូច្នេះ ក្រុមហ៊ុនត្រូវសិក្សាអំពីបរិមាណ និងលទ្ធភាពនៃការបំលែងទៅជាអាស៊ីដដែលមានកំហាប់ខ្ពស់នេះ។ (៣) សិក្សាអំពីកំហាប់លោហៈធុនធ្ងន់ដែលអាចរលាយបានហៅកាត់ថា AMD (Acid Mine Drainage) ដែលជាធម្មតាអាស៊ីដនេះមានកំហាប់អ៊ីយ៉ុងអ៊ីដ្រូសែន (ប៉ូតង់ស្យែលអ៊ីដ្រូសែន – pH) រហូតដល់៣ ឬទាបជាង។ កាកសំណល់ទាំងនេះ អាចបង្កអោយមានការផ្លាស់ប្តូរអំពីលក្ខណៈកេ្សត្រគីមីជីវៈរបស់ដីនៅជុំវិញនោះ ប្រសិនបើគ្មានការរៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ (Tailing Impoundment Systems) អោយបានត្រឹមត្រូវទេនោះ។ និង (៤) ប្រសិនបើនៅគំនរអាចម៍រ៉ែសម្បូរណ៍ទៅដោយ Sulfur និង AMD នោះ មុនរៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ (Tailing Impoundment Systems) ក្រុមហ៊ុនត្រូវរកទីកន្លែង អោយបានសមស្របជាមុនសិន។ កន្លែងដែលសមស្របសម្រាប់ការរៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ ចាំបាច់ត្រូវនៅដាច់ពីគេ ហើយត្រូវបញ្ចៀសទឹកដែលជ្រាបចេញពីគំនរអាចម៍រ៉ែ មិនអោយហូរចូល និងបំពុលដល់ទឹកស្រទាប់លើនិងទឹកក្រោមដី។ មិនត្រឹមតែប៉ុណ្ណោះប្រព័ន្ធនេះ ត្រូវរៀបចំយ៉ាងណាដើម្បីកាត់បន្ថយការហូររបស់ទឹកសាប (ទឹកភ្លៀង ឬទឹកពីប្រភពផ្សេងៗទៀត) បន្ទាប់មកត្រូវធ្វើប្រព្រឹត្តកម្មទៅលើទឹកសំណល់ទាំងនោះដើម្បីកាត់បន្ថយកំហាប់អ៊ីយ៉ុងអ៊ីដ្រូសែន (កាត់បន្ថយការបញ្ចេញចោលមួយដែលមានជាតិពុលខ្ពស់) ទៅតាមលទ្ធភាពមួយដែលអាចធ្វើទៅបាន។ ជាអនុសាសន៍ ក្រុមហ៊ុនត្រូវរៀបចំប្រព័ន្ធចង្វាក់ផលិតកម្ម ក្នុងនោះមានទាំងការរៀបចំនូវកន្លែងរក្សា និងការពារកាកសំណល់រឹង និងប្រព័ន្ធធ្វើប្រព្រឹត្តកម្មសំណល់រាវ អោយបានចប់សព្វគ្រប់មុននឹងដំណើរការ

អាជីវកម្មរ៉ែមាសនៅក្នុងតំបន់នេះ។ ក្រោយការរៀបចំចប់សព្វគ្រប់ ក្រុមហ៊ុនត្រូវដាក់ផែនការផលិតកម្ម ក្នុងនោះមានទាំងប្រតិបត្តិការប្រព័ន្ធប្រព្រឹត្តកម្មសំណល់រឹង និងរាវមកអោយក្រសួងពិនិត្យ ដើម្បីបញ្ជាក់អំពីសមត្ថភាពរបស់ប្រព័ន្ធនៅក្នុងដំណើរប្រព្រឹត្តកម្មសំណល់រឹងនិងរាវ ដែលកើតមានពីដំណើរការអាជីវកម្មរ៉ែមាស ទើបអាចធានាបានថា សកម្មភាពពីដំណើរការអាជីវកម្មរ៉ែមាសនៅក្នុងតំបន់នេះ ពិតជាមិនធ្វើអោយប៉ះពាល់ទៅលើលក្ខណៈភៅគ្រុតិមីជីវៈរបស់ដី និងការបំពុលទឹកស្រទាប់លើ និងស្រទាប់ក្រោមនៅក្នុងតំបន់។

សូមអង្គប្រជុំជ្រាបនេះគ្រាន់តែជាការពិគ្រោះយោបល់គ្នា ដើម្បីកែលំអរបាយការណ៍វាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមដំបូងតែប៉ុណ្ណោះ មុនពេលដែលក្រសួងបរិស្ថានចេញលិខិតអនុញ្ញាតអោយទៅក្រុមហ៊ុន ដូចនេះមានការប្រជុំឆ្លងបីដងទៀត (១) ប្រជុំអន្តរនាយកដ្ឋានរបស់ក្រសួងបរិស្ថាន (២) ប្រជុំថ្នាក់ដឹកនាំក្រសួងបរិស្ថាន និង (៣) ប្រជុំថ្នាក់អន្តរក្រសួង ពេលនោះគឺថ្នាក់ដឹកនាំខេត្តត្រូវបានអញ្ជើញចូលរួមដែរ អាចអភិបាលរងខេត្តទទួលបន្ទុក ឬអភិបាលស្រុក បើចាំបាច់អញ្ជើញចូលរួមគ្រប់ករណីទាំងអស់ បានន័យថាលំអិតខ្លាំងណាស់។ ចំនុចទី៣ វិធានការណ៍ការពារផលប៉ះពាល់ ខ្ញុំសូមជំរាបគឺលំអិតខ្លាំងណាស់ មុននឹងបញ្ចេញ កាកសំណល់អោយតែក្រុមហ៊ុនសហការជាមួយជំនាញបានត្រឹមត្រូវនោះផលប៉ះពាល់ដែលបង្កឡើងអាចកាត់បន្ថយដល់កំរិត ខ្ញុំជឿជាក់ទៅលើក្រុមហ៊ុន ដែល ឌុម (កម្ពុជា) ព្រោះគាត់អាស្រ័យជាមួយជំនាញហើយបានគាត់ធ្វើ។ ប្រពន្ធ័មួយដែលយើងធ្វើប្រព្រឹត្តកម្មសំណល់រាវចេញពីអាងដែលយើងទាញយកមាសសុទ្ធមកអោយហៅថា ប្រពន្ធ័ដែលធ្វើអោយរងនៅក្នុងនឹងទោះបីអាស៊ីដស្យាណែតមានកំហាប់ខ្ពស់ក៏ដោយ ប៉ុន្តែដល់ពេលចុងក្រោយអាស៊ីតនឹងត្រូវបានរលាយ ហើយកាកសំណល់អាស៊ីដស្យាណែតបានរងចុះទៅក្រោម ដូច្នេះសំណល់រាវដែលចេញពីអាងប្រព្រឹត្តកម្មដកយករ៉ែមាសចេញមកគឺឆ្លងកាត់ប្រពន្ធ័ចំរោះច្រើន ហើយដល់ពេលចុងក្រោមវាស្ថិតនៅក្នុងប្រពន្ធ័មួយទៀតដែលគេអាចចិញ្ចឹមត្រីបាន បើត្រីនៅក្នុងប្រពន្ធ័អាចរស់បានទើបទឹកនឹងអាចបញ្ចេញទៅក្នុងធម្មជាតិបាន។ ជាក់ស្តែងយើងលើជាចំនុចគោល១ ដោយសារដំហ៊ានដំបូង នៅមួយជំហ៊ានទៀត ពេលដែលក្រុមហ៊ុនឈានទៅធ្វើអាជីវកម្មការវាយតំលៃពេញលេញត្រូវបានវាយតំលៃហើយកាត់បន្ថយផលប៉ះពាល់ត្រូវបានលំអិតនៅពេលហ្នឹង។ ចំនុចទី៤ ខ្ញុំគិតថាក្រុមហ៊ុនអាចធ្វើលិខិតមួយទៅក្រសួងកសិកម្ម ហើយផ្ញើរមករដ្ឋបាលព្រៃឈើ ខ្ញុំសូមជំរាបការធ្វើរ៉ែនេះខុសពីការធ្វើអាជីវកម្មរ៉ែបើករណ្តៅ ថ្មី១កាលពីថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១០ មានការប្រជុំរឿងក្រុមហ៊ុន សំណាងរ៉ែ នៅស្រុកថ្មបាំង និងស្រុកស្រែអំបិលគាត់នឹងធ្វើការបើករណ្តៅប្រមាណជា ៥៣ហិកតារៀងរាល់ឆ្នាំ សរុបនៅលើផ្ទៃដី ៣៦០០ហិកតា មានរយៈពេលជាង៤០ឆ្នាំ ប៉ុន្តែគាត់អត់បានអាស្រ័យនឹងក្រសួងកសិកម្ម ដូច្នេះក្រសួងកសិកម្មបានលើកឡើងធ្វើយ៉ាងម៉េច? ពីព្រោះបើមានការឈូសឆាយគំរបព្រៃ១០០ភាគរយ តំរូវអោយធ្វើការវាយតំលៃឈើឈរ ដើម្បីអោយបង់ពន្ធចូលរដ្ឋ ប៉ុន្តែករណីក្រុមហ៊ុន ដែល ឌុម មានតែ ២ហិកតាទេ។

ចំនុចទី៥ ការប្រើប្រាស់គ្រឿងផ្ទុះ នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននៅត្រង់ចំនុចមួយយើងបានសរសេរអំពី ថាតើមានវិធានការណ៍ណាខ្លះដើម្បីរក្សាបាននូវសុវត្ថិភាពបុគ្គលិកនៅពេលម្សៅផ្ទុះ? ការប្រើម្សៅផ្ទុះរបស់ក្រុមហ៊ុន **ដែល ខុម (កម្ពុជា)** តាមខ្សែរ៉ែមាសដែលស្ថិតនៅខាងក្រោមតែប៉ុណ្ណោះដោយខ្សែរ៉ែមាសនេះមានទំហំតូចអណ្តូងរ៉ែដែលយើងជីកចុះទៅអត់មានច្រើនទេ។ ដូច្នេះមិនចាំបាច់ថា នៅពេលបិទរណ្តៅយើងប្រើម្សៅផ្ទុះទៅរណ្តៅនឹង ឬមួយយ៉ាងណា ប៉ុន្តែទាក់ទងនឹងសុវត្ថិភាពផ្សេងៗដល់ប្រជាជន ដែលរស់នៅក្នុងតំបន់នោះ ខ្ញុំគិតថាស្ទើរតែគ្មាន ពីព្រោះយើងប្រើម្សៅផ្ទុះគឺនៅខាងក្រោម ហើយតំបន់នឹងវាឆ្ងាយពីទីប្រជុំប្រមាណ ៤-៥គីឡូម៉ែត្រ ពីភូមិរំដេងដែលជាភូមិឧបសម្ព័ន្ធភូមិទន្ទឹម ហើយដោយសារមានព្រៃឈើពទ្ធ័ជុំវិញទៀតសំលេងដែលបង្កឡើងដោយការបំផ្ទុះនោះគឺ អត់មានបញ្ហាអីទេ។ ដោយឡែកទៅទៀតម្សៅផ្ទុះមិនមែនចេះតែប្រើប្រាស់ទេ ការទិញសុទ្ធតែឆ្លងកាត់ក្រសួងមហាផ្ទៃហើយចំនួនបរិមាណ និងការប្រើប្រាស់ត្រូវច្បាស់លាស់តែម្តង។ ចំនុចទី៦ ជាទូទៅគ្រប់គំរោងវិនិយោគទាំងអស់ឆ្លងកាត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ កំណត់អោយមានមូលនិធិដើម្បីធ្វើការអភិវឌ្ឍន៍សំរាប់សហគមន៍ (១) អាចមើលទៅលើបញ្ហាទឹកស្អាត (២)ផ្លូវលំជនបទ (៣) មណ្ឌលសុខភាព (៤)សាលារៀន បើករណីចាំបាច់យើងត្រូវមានកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដូច្នេះគ្រាន់តែកម្មវិធីនឹងមិនទាន់ត្រូវបានរៀបចំទេ ដល់ពេលត្រលប់ទៅវិញ ខ្ញុំរៀបចំរបាយការណ៍ដាក់ទៅក្រសួងបរិស្ថានបានមូលនិធិអភិវឌ្ឍន៍សហគមន៍បានកំណត់។ នៅពេលប្រជុំអន្តរក្រសួង ក្រសួងសេដ្ឋកិច្ចអោយក្រុមហ៊ុនធ្វើការបំភ្លឺ ឬត្រូវតំកល់លុយនៅក្នុងក្រសួង ឬមួយយ៉ាងណានោះ យើងត្រូវជជែកគ្នាបន្តទៅទៀត ហើយលុយនេះត្រូវបានយកមកប្រើប្រាស់នៅក្នុងសហគមន៍ផ្ទាល់តែម្តង ដូច្នេះប្រសិនបើក្រុមហ៊ុនអនុវត្តន៍ទៅតាមអ្វីដែលជាវិធានការណ៍ផលប៉ះពាល់ទៅលើសហគមន៍មូលដ្ឋាន ខ្ញុំគិតថាបងប្អូនជនជាតិនៅតំបន់នោះពួកគាត់ស្វាគមន៍។ មួយទៀតនៅពេលដំណើរការអាជីវកម្មក្រុមហ៊ុនត្រូវការបុគ្គលិកកម្មករ ប្រសិនជាប្រជាជននៅក្នុងតំបន់នឹងគាត់មានស្មារតីវាបង្កអោយមានចរន្តសេដ្ឋកិច្ចនៅក្នុងតំបន់ ដូច្នេះតំរូវស្បៀងអាហារ ជ្រូក មាន់ ទា បន្លែ នេះជាផ្នែកដើម្បីជួយលើកកំពស់ជីវភាពរបស់ប្រជាជននៅក្នុងតំបន់។

លោក **ឡៅម ម៉ុនថា** តំណាងក្រុមហ៊ុន Delcom (Kampuchea) PTE. LTD. បានឆ្លើយតបចំពោះការសំណួមពររបស់មន្ទីរបរិស្ថាន រដ្ឋបាលព្រៃឈើ មន្ទីរឧស្សាហកម្ម និងលោកអភិបាលស្រុករវៀងថានឹងធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយគ្នា ដើម្បីជៀសវាងមានបញ្ហានៅថ្ងៃអនាគត។

កិច្ចប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោង ១១និង៣០នាទី នៅថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយស្និទ្ធស្នាល និងយោគយល់គ្នា ។

ធ្វើនៅព្រះវិហារ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០

អ្នកធ្វើកំណត់ហេតុ

ហត្ថលេខា

**អ៊ុន ចាន់ណារ៉ូ**

Draft

## កំណត់ហេតុរបាយការណ៍ស្តីពីការពិគ្រោះយោបល់ជាមួយ ថ្នាក់ដឹកនាំស្រុក ឃុំ-ភូមិ និងប្រជាពលរដ្ឋពាក់ព័ន្ធ (ជាមតិ និងសំណូមពរ)

- លោក **ង៉ សារ៉ូ** អភិបាលស្រុករវៀង: ខ្ញុំបានដឹងពីគម្រោងនេះ ព្រោះក្រុមហ៊ុន ដែលខុម( កម្ពុជា) ភីធីអ៊ី បានស្រាវជ្រាវរុករករ៉ែ មាសនៅតំបន់ភ្នំនេះតាំងពីឆ្នាំ២០០៤មកម្ល៉េះ រហូតមកដល់ឆ្នាំ២០០៩ ក៏ឈប់ដំណើរការរុករក។ ចំពោះផលប៉ះពាល់សង្គមលើគំរោងនេះឃើញថា ពុំមានផលប៉ះពាល់អ្វីជាមួយប្រជាជនដែលរស់នៅតំបន់នេះទេ ដោយសារគំរោងរុករករ៉ែរបស់ក្រុមហ៊ុននៅឆ្ងាយពីភូមិ និងការប្រកបមុខរបររបស់ពួកគាត់។ ប្រជាជនក្នុងតំបន់នេះក្រោយពីការធ្វើស្រែ-ចំការរួច ពួកគាត់នាំគ្នាទៅរកមាសនៅក្បែរជើងភ្នំអន្លង់ដោយមួយថ្ងៃអ្នកខ្លះអាចរកបាន១លី អ្នកខ្លះក៏អត់បាន ដោយសារពួកគាត់អត់មានឧបករណ៍អ្វីក្រៅតែពីថាស និងទរសំរាប់រែង។ ចំណែកឯ ព្រៃឈើនៅតំបន់នោះអត់មានប៉ះពាល់ទេ ព្រោះដីដែលក្រុមហ៊ុនសាងសង់ការស្នាក់នៅ និងអណ្តូងរុករករ៉ែ ពេលបច្ចុប្បន្នប្រើប្រាស់ដីប្រមាណជា២ហិកតាតែប៉ុណ្ណោះ ហើយស្ថានភាពព្រៃនៅតំបន់នោះភាគច្រើនសុទ្ធតែជាព្រៃល្បោះមួយដើម។ ចំពោះសត្វព្រៃមិនជាបញ្ហាចោទប៉ុន្មានទេ ព្រោះតំបន់ស្រាវជ្រាវរុករករ៉ែមានទំហំតូច សត្វអាចបំលាស់ទីទៅតំបន់ក្បែរៗហ្នឹង។ រីឯបញ្ហាចោទទឹកអូរ កាលណាក្រុមហ៊ុនធ្វើអាជីវកម្មរុករករ៉ែតែងតែត្រូវការទឹកសំរាប់ប្រើប្រាស់ ដើម្បីកុំអោយមានផលប៉ះពាល់ដល់ប្រភពដែលស្ថិតនៅក្នុង ឬក្បែរតំបន់រុករករ៉ែមាស ក្រុមហ៊ុនត្រូវធ្វើចំរោះទឹកយ៉ាងម៉េចកុំអោយមានជាតិពុល។ សូមក្រុមហ៊ុនធ្វើអាជីវកម្មរុករករ៉ែអោយស្របតាមបទដ្ឋានបច្ចេកទេសអោយបានត្រឹមត្រូវ ដូចជា ធ្វើអាងស្តុកទឹកដែលហូរចេញពីកន្លែងរែងយករ៉ែ ដើម្បីទប់ស្កាត់កុំអោយមានផលប៉ះពាល់ដល់ប្រភពទឹកនៅតំបន់នោះ។

Draft

- លោក **ឈន់ ជា** មេឃុំរម្យទម : តាមការពិនិត្យផែនទីដែលក្រុមហ៊ុនស្នើសុំរុករករ៉ែ ឃើញថានៅឆ្ងាយពីភូមិករ និងដីស្រែចំការរបស់ប្រជាពលរដ្ឋ ប៉ុន្តែអាចប៉ះពាល់ដល់របរជីករ៉ែមាសរបស់ពួកគាត់មួយចំនួនតូចដែលធ្លាប់ទៅរកនៅតំបន់នោះ ព្រោះប្រជាពលរដ្ឋក្នុងឃុំរម្យទមក្រោយពីការប្រកបមុខរបរធ្វើស្រែចំការរួច ពួកគាត់នាំគ្នាទៅរកជីករ៉ែមាសក្បែរជើងភ្នំអន្លង់ម្តុំតំបន់រុករករ៉ែមាសរបស់ក្រុមហ៊ុន។ ពួកគាត់ប្រើប្រាស់ថាស ម្ទទរ ជាឧបករណ៍សំរាប់រែងយករ៉ែមាស (រ៉ែដែលគាត់រែងបានក្នុង ១ដីអាចលក់បានពី ៥៥-៦០ម៉ឺនរៀល) នេះជាមុខរបរបន្ទាប់បន្សំក្រៅពីស្រែចំការ។ នៅក្នុងឃុំនេះមានអង្គការជួយអភិវឌ្ឍន៍ដូចជា: អង្គការ ADRA(ជួយផ្នែកអណ្តូងទឹក ស្រះចិញ្ចឹមត្រី និងកសិកម្ម) Worldvision (ជួយផ្នែកហេដ្ឋារចនាសម្ព័ន្ធ) និង ពុទ្ធសាសនា (ជួយផ្នែកអប់រំ)។

- លោក **ស៊ិន ថន** មេប៉ុស្តិ៍នគរបាលឃុំរម្យទម: នៅក្នុងឃុំរម្យទមភាគច្រើនជាជនជាតិភាគតិចកួយ ដែលពួកគាត់រស់នៅតាំងពីដូនតាមកម្លេះ ក្រោយពីប្រកបរបរធ្វើស្រែចំការរួច ពួកគាត់នាំគ្នាទៅរករ៉ែមាសនៅក្បែរតំបន់ជើងភ្នំអន្លង់ និងរែងមាសតាមដងអូរ ដើម្បីជួយទ្រទ្រង់ជីវភាពគ្រួសារបន្ថែម ។ ឃុំទាំងមូលពុំទាន់មានមណ្ឌលសុខភាពនៅឡើយ មានតែប៉ុស្តិ៍សុខភាពមួយកន្លែងស្ថិតនៅភូមិស្វាយដំណាក់ចាស់ ទោះបីជាយ៉ាងនេះក្តីនៅពេលមានសមាជិកគ្រួសារណាជំងឺត្រូវដឹកជញ្ជូនទៅមណ្ឌលសុខភាពឃុំរម្យណី ឬទៅមន្ទីរពេទ្យបង្អែកខេត្ត ។ សូមក្រុមហ៊ុនដែលចូលមកវិនិយោគនៅក្នុងតំបន់ជួយអភិវឌ្ឍន៍ភូមិ ឃុំដូចជា: សាងសង់សាលារៀន អណ្តូងទឹកស្អាត ផ្លូវ( ពីភូមិស្វាយដំណាក់ថ្មីមកផ្លូវជាតិលេខ៦២) មណ្ឌលសុខភាព....... ។ល ។

Draft